# សេរីភាពសារព័ត៌មាន




ខែឧសភា ឆ្នាំ២០២២

ផលិតដោយៈ

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

គាំទ្រដោយៈ

USAID
ជំនួយពីពលរដ្ឋអាមេរិក

## អំពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») គឺជាអង្គការមិនមែនរដ្ឋាភិបាល មិនចូលបក្សសម្ព័ន្ធ ឯករាជ្យ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅប្រទេសកម្ពុជា។ ទស្សនៈវិស័យរបស់ ម.ស.ម.ក គឺកម្ពុជាគ្មានអំពើហិង្សា ដែលប្រជាពលរដ្ឋទទួលបានសិទ្ធិជាមូលដ្ឋាន និងត្រូវបានផ្តល់អំណាចដើម្បីចូលរួមក្នុងលទ្ធិប្រជាធិប តេយ្យ និងទទួលបានការចែករំលែកផលប្រយោជន៍ពីការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសកម្ពុជា។ ម.ស.ម.ក លើកកម្ពស់នីតិរដ្ឋជាជាងនិទណ្ឌភាព ស្ថាប័នរឹងមាំជាជាងបុគ្គលខ្លាំង និងសង្គមសេរីពហុបក្សដែលភាពចម្រុះត្រូវបានស្វាគមន៍ និងអបអរសាទរជាជាងការមិនអើពើ និងការដាក់ទោស។ រូបសញ្ញាសម្គាល់របស់ ម.ស.ម.ក គឺរូបសត្វព្រាបពណ៌សកំពុងហើរបំបែកចេញពីរង្វង់មូលពណ៌ផ្ទៃមេឃ ដែលតំណាងឱ្យគោលការណ៍សន្តិភាព និងសេរីភាព។

## សេចក្តីថ្លែងអំណរគុណ

មេរៀនសេរីភាពសារព័ត៌មាននេះត្រូវបានរៀបចំឡើងដោយ ម.ស.ម.ក។ មេរៀននេះអាចកើតចេញជារូបរាងឡើងដោយសារមានការគាំទ្រដោយសប្បុរសអំពីសំណាក់ ទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិនៃសហរដ្ឋអាមេរិក។ ខ្លឹមសារនៃមេរៀននេះគឺជាការទទួលខុសត្រូវរបស់ ម.ស.ម.ក និងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិនៃសហរដ្ឋអាមេរិកឡើយ។

## អំពីមេរៀនស្តីពីសេរីភាពសារព័ត៌មាន

មេរៀនស្តីពីសេរីភាពសារព័ត៌មាននេះត្រូវបានផលិតឡើងជាផ្នែកមួយរបស់គម្រោង "បង្កើនការគោរពសិទ្ធិនៅកម្ពុជា" ដើម្បីលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋកម្ពុជាអំពីសារៈសំខាន់នៃសេរីភាពសារព័ត៌មាន។ មេរៀននេះពណ៌នា អំពីនិយមន័យនៃសេរីភាពសារព័ត៌មាន និងសារៈសំខាន់នៃសេរីភាពនេះ ក្របខ័ណ្ឌច្បាប់ស្តីពីសេរីភាពសារព័ត៌មានតាមច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ។ មេរៀននេះក៏ពិភាក្សាអំពីការកំណត់របស់ច្បាប់ចំពោះសេរីភាពសារព័ត៌មាននៅកម្ពុជាផងដែរ។

## ចម្ងល់ និងមតិចូលរួម

ប្រសិនបើលោកអ្នកមានសំណួរ ឬត្រូវការព័ត៌មានបន្ថែមពាក់ព័ន្ធនឹងមេរៀននេះ សូមទាក់ទងមកកាន់ ម.ស.ម.ក តាមរយៈ៖

អាសយដ្ឋាន៖ ផ្ទះលេខ៧៩៨ ផ្លូវ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ៖ ៨៥៥ (០) ២៣ ៧២៦ ៩០១

គេហទំព័រ៖ www.cchrcambodia.org

## មាតិកា


១. សេចក្តីផ្តើម ..................................................១

២. តើសេរីភាពសារព័ត៌មានជាអ្វី? ..................................................១

៣. ហេតុអ្វីបានជាសេរីភាពសារព័ត៌មានមានសារៈសំខាន់? ..................................................១

៤. ការគំរាមកំហែងដល់សេរីភាពសារព័ត៌មានជុំវិញពិភពលោក ..................................................៤

៥. សេរីភាពសារព័ត៌មាននៅប្រទេសកម្ពុជា ..................................................៥

៦. សេរីភាពសារព័ត៌មានក្រោមច្បាប់ជាតិ និងច្បាប់អន្តរជាតិ ..................................................៦

៧. កំហិតផ្នែកច្បាប់ចំពោះសេរីភាពសារព័ត៌មាននៅកម្ពុជា ..................................................៧

សំណួរសាកល្បង ..................................................៩

# សេរីភាពសារព័ត៌មាន

# សេរីភាពសារព័ត៌មាន

## ១. សេចក្តីផ្តើម

សេរីភាពសារព័ត៌មាន ឬសេរីភាពប្រព័ន្ធផ្សព្វផ្សាយគឺជាមូលដ្ឋានគ្រឹះនៃសង្គមប្រជាធិបតេយ្យ។ សេរីភាពនេះអនុញ្ញាតឱ្យប្រជាពលរដ្ឋស្វែងរក និងផ្សព្វផ្សាយព័ត៌មាន គំនិត យោបល់ និងមតិនានា។ សារព័ត៌មានក៏ផ្តល់ជាវេទិកាធ្វើឱ្យស្តាប់បានឮនូវសំឡេងជាច្រើនផងដែរ។ សារព័ត៌មានត្រូវបានប្រើប្រាស់ដើម្បីត្រួតពិនិត្យពីតម្លាភាព និងគណនេយ្យភាពដែលរដ្ឋាភិបាលត្រូវអនុវត្ត។ ដូច្នេះ សារព័ត៌មានសេរី និងឯករាជ្យធានានូវនីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យ។

## ២. តើសេរីភាពសារព័ត៌មានជាអ្វី?



សេរីភាពសារព័ត៌មានសំដៅដល់ការចែកចាយ និងផ្សព្វផ្សាយព័ត៌មានតាមរយៈវិទ្យុ និងទូរទស្សន៍ ក្នុងទម្រង់បោះពុម្ពជាកាសែត ឬទស្សនាវដ្តី តាមប្រព័ន្ធផ្សព្វផ្សាយសង្គម ឬប្រព័ន្ធឌីជីថលផ្សេងទៀត ដោយមិនមានការជ្រៀតជ្រែកពីរដ្ឋាភិបាល ឬភាគីទីបី។ សេរីភាពសារព័ត៌មានជំរុញឱ្យមានសេរីភាពក្នុងការបញ្ចេញមតិ និងជួយឱ្យសង្គមប្រជាធិបតេយ្យរីកចម្រើន។ សេរីភាពសារព័ត៌មានគឺជាសិទ្ធិដែលត្រូវបានការពារដោយសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ និងរដ្ឋធម្មនុញ្ញកម្ពុជា។

## ៣. ហេតុអ្វីបានជាសេរីភាពសារព័ត៌មានមានសារៈសំខាន់?

សារព័ត៌មានសេរីមានសារៈសំខាន់ណាស់សម្រាប់សង្គមប្រជាធិបតេយ្យ។ សារព័ត៌មានសេរីអនុញ្ញាតឱ្យសង្គមអនុវត្តសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិរបស់ខ្លួន ដែលជាសិទ្ធិមូលដ្ឋានរបស់មនុស្ស។ សារព័ត៌មានសេរី ស៊ើបអង្កេតបញ្ហានានាដើម្បីផ្សព្វផ្សាយជាព័ត៌មាន គំនិត មតិយោបល់ និងទស្សនៈនានា ដែលជួយឱ្យរដ្ឋាភិបាលទទួលខុសត្រូវចំពោះសកម្មភាព ឬបង្ហាញពីកំហុសរបស់ខ្លួន។ សារព័ត៌មានសេរីមិនត្រឹមតែមានមុខងារជាអ្នកឃ្លាំមើលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យប្រជាពលរដ្ឋបានដឹងអំពីព័ត៌មានដែលមានសារៈសំខាន់សម្រាប់ផលប្រយោជន៍សាធារណៈ ដែលនាំឱ្យប្រជាធិបតេយ្យរឹងមាំ។




- **សារព័ត៌មានសេរីជួយផ្ដល់ដំណឹងដល់សាធារណជន**

ចំណេះដឹងគឺជាអំណាច ហើយបើគ្មានការចែករំលែកព័ត៌មានដោយសេរីតាមរយៈការបោះពុម្ព ទូរទស្សន៍ វិទ្យុ ឬតាមអនឡាញទេនោះ ប្រជាពលរដ្ឋនឹងមិនដឹងពីស្ថានភាពប្រជាធិបតេយ្យក្នុងសង្គមរបស់ខ្លួន ឬអំពីបញ្ហាដែលអាចប៉ះពាល់ដល់ពួកគេឡើយ។ កង្វះព័ត៌មានមានន័យថាបុគ្គលម្នាក់ៗមិនអាចចូលរួមដោយពេញលេញនៅក្នុងសហគមន៍របស់ពួកគេ ឬនៅក្នុងដំណើរការសម្រេចចិត្តឡើយ។ សេរីភាពសារព័ត៌មានអនុញ្ញាតឱ្យមានការអនុវត្តសិទ្ធិទទួលព័ត៌មាន ដែលផ្ដល់សិទ្ធិអំណាចដល់សង្គមក្នុងការស្វែងយល់អំពីបញ្ហានៃផលប្រយោជន៍សាធារណៈសំខាន់ៗ។ នៅពេលដែលសេរីភាពសារព័ត៌មានត្រូវបានគោរព និងទទួលស្គាល់ នោះប្រព័ន្ធផ្សព្វផ្សាយ និងបុគ្គលនានាអាចរាយការណ៍បានដោយសេរីអំពីនយោបាយ សេដ្ឋកិច្ច និងព្រឹត្តិការណ៍សង្គមសំខាន់ៗផ្សេងទៀត។

- **សារព័ត៌មានសេរីផ្ដល់ព័ត៌មានដល់អ្នកបោះឆ្នោត និងពង្រឹងប្រជាធិបតេយ្យ**




លទ្ធិប្រជាធិបតេយ្យអាចរីកចម្រើនទៅបាន នៅពេលដែលអ្នកបោះឆ្នោតទទួលបានព័ត៌មានពេញលេញ។ ពួកគេអាចយល់ពីបញ្ហាដែលប៉ះពាល់ដល់ខ្លួន និងបញ្ហាសាធារណៈសំខាន់ៗ ដែលអនុញ្ញាតឱ្យពួកគេធ្វើការជ្រើសរើសប្រកបដោយការយល់ដឹងខ្ពស់។ សារព័ត៌មានសេរីជួយឱ្យសង្គមស្គាល់ពីគោលនយោបាយ និងអ្នកនយោបាយ និងជួយឱ្យអ្នកបោះឆ្នោតធ្វើការសម្រេចចិត្តថាតើនរណាជាតំណាងដ៏ល្អបំផុតរបស់ពួកគេ។ អ្នកសារព័ត៌មានឯករាជ្យជួយផ្ដល់ព័ត៌មានដល់សង្គមតាមរយៈការស៊ើបអង្កេតបញ្ហា ការវិភាគព័ត៌មាន ជំរុញឱ្យមានការពិភាក្សា និងការផ្ទៀងផ្ទាត់ព័ត៌មានជាដើម។ នៅពេលមានសារព័ត៌មានសេរី សង្គមនឹងទទួលបានព័ត៌មានកាន់តែប្រសើរ និងមិនរងឥទ្ធិពលនយោបាយ ដែលប្រការនេះជួយដល់ដំណើរការលទ្ធិប្រជាធិប តេយ្យឱ្យបានប្រសើរឡើង។

- **ការលាតត្រដាងការពិត**




គន្លឹះសំខាន់នៃសារព័ត៌មានឯករាជ្យ និងសារព័ត៌មានសេរី គឺអាចមានលទ្ធភាពក្នុងការស៊ើបអង្កេតឱ្យបានហ្មត់ចត់ទៅលើបញ្ហា ដើម្បីរាយការណ៍ពីបញ្ហានោះឱ្យបានត្រឹមត្រូវ។ តាមរយៈការស៊ើបអង្កេត សារព័ត៌មានសេរីអាចនាំយកព័ត៌មាននោះទៅបង្ហាញជាសាធារណៈ។ ព័ត៌មានត្រឹមត្រូវមានសារៈសំខាន់សម្រាប់ការពិភាក្សាដេញដោលជាសាធារណៈនិងចំពោះសង្គមប្រជាធិបតេយ្យ ព្រោះព័ត៌មានមានឥទ្ធិពលលើ គោលនយោបាយនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងអន្តរជាតិ។

- **សារព័ត៌មានឯករាជ្យអាចធ្វើឱ្យអ្នកមានអំណាចមានគណនេយ្យភាព**

ការរាយការណ៍ដោយឯករាជ្យដើរតួយ៉ាងសំខាន់ក្នុងការធានាតុល្យភាពអំណាចនៃលទ្ធិប្រជាធិតេយ្យ។ សារព័ត៌មានឯករាជ្យ និងត្រឹមត្រូវអាចជួយឱ្យបុគ្គល ឬស្ថាប័នដែលមានអំណាច និងទ្រព្យសម្បត្តិ មានគណនេយ្យភាពបាន។ សារព័ត៌មានបែបស៊ើបអង្កេតស៊ីជម្រៅទទួលបានការចាប់អារម្មណ៍ពីសាធារណជន អាចលើកកម្ពស់ដល់ការពិនិត្យពិច័យ និងដោះស្រាយអំពើពុករលួយ ឬការរំលោភសិទ្ធិមនុស្ស។ ប្រព័ន្ធផ្សព្វផ្សាយរឹងមាំ និងឯករាជ្យ ជានានូវតម្លាភាព និងគណនេយ្យភាព។



- **បើគ្មានសេរីភាពសារព័ត៌មាន នោះការរាយការណ៍ឯករាជ្យត្រូវបានរាំង**



កន្លែងណាដែលសេរីភាពសារព័ត៌មានមិនត្រូវបានគោរពទេនោះ អ្នកសារព័ត៌មានឯករាជ្យត្រូវដាក់កំហិតខ្លួនឯង បើមិនដូច្នោះទេ ស្ថានភាពជីវភាព ឬក៏សុវត្ថិភាពរបស់ពួកគេអាចជួបហានិភ័យ។ នៅពេលដែលប្រព័ន្ធផ្សព្វផ្សាយមិនអាចរាយការណ៍អំពីបញ្ហាបានត្រឹមត្រូវដោយសារតែការភ័យខ្លាចការតេបតផ្នែកច្បាប់ ឬបទព្រហ្មទណ្ឌ អ្នកសារព័ត៌មានជ្រើសរើមិនរាយការណ៍រឿងរ៉ាវឱ្យបានពេញលេញ ឬជ្រើសរើសរាយការណ៍លើប្រធានបទណាដែលមាន“សុវត្ថិភាព”ជំនួសវិញ។ កត្តានេះធ្វើឱ្យប៉ះពាល់ដល់លំហូរព័ត៌មានសេរី និងនាំឱ្យសាធារណជនទទួលបានព័ត៌មានមិនគ្រប់ជ្រុងជ្រោយអំពីបញ្ហាប្រយោជន៍សាធារណៈ។ ការគោរពសេរីភាពក្នុងការបញ្ចេញមតិគឺជាធាតុសំខាន់មួយសម្រាប់ការប្រព្រឹត្តទៅ និងភាពត្រឹមត្រូវនៃប្រព័ន្ធផ្សព្វផ្សាយ។

- **សេរីភាពសារព័ត៌មានបើកផ្លូវដល់សិទ្ធិមនុស្សផ្សេងៗទៀត**




សេរីភាពសារព័ត៌មានអាចឱ្យមានការទទួលស្គាល់សិទ្ធិមនុស្សផ្សេងទៀត។ សារព័ត៌មានសេរីអាចលាតត្រដាងការរំលោភសិទ្ធិមនុស្ស ដូចជាការធ្វើទារុណកម្ម ការរើសអើងលើស្ត្រី ឬស្ត្រីស្រលាញ់ស្ត្រី បុរសស្រលាញ់បុរស អ្នកស្រលាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ អន្តរភេទ និងអ្នកដែលមិនកំណត់អត្តសញ្ញាណខ្លួនឯងចូលទៅក្នុងផ្នែកណាមួយ(«អ្នកស្រឡាញ់ភេទដូចគ្នា») ឬការរំលោភសិទ្ធិដីធ្លី ដែលនេះគ្រាន់តែជាការរៀបរាប់មួយចំនួនប៉ុណ្ណោះ។ សេរីភាពសារព័ត៌មានក៏នាំឱ្យមានសិទ្ធិសេរីភាពក្នុងការជួបប្រជុំ និងសមាគម និងជួយសម្រួលដល់ការចូលរួមរបស់ពលរដ្ឋផងដែរ។ ក្នុងករណីដែលគ្មានការរាយការណ៍ដោយសេរី និងត្រឹមត្រូវទេនោះ ការរំលោភសិទ្ធិមនុស្សជាច្រើននឹងនៅតែបន្តលាក់បាំង។ សេរីភាពសារព័ត៌មានអនុញ្ញាតឱ្យប្រជាពលរដ្ឋនិយាយចេញនូវគំនិតរបស់ខ្លួនដោយសេរី និងចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យ។ សេរីភាពនេះក៏ផ្តល់សិទ្ធិអំណាចដល់សហគមន៍រងគ្រោះធ្វើការតស៊ូមតិដើម្បីសិទ្ធិរបស់ពួកគេដែលអាចបង្កើតឱ្យមានការផ្លាស់ប្តូរជាក់ស្តែងនៅក្នុងគោលនយោបាយរបស់រដ្ឋាភិបាល។

- **បញ្ហារបស់ក្រុមរងគ្រោះ និងជនជាតិភាគតិចកាន់តែអាចមើលឃើញច្បាស់**



សេរីភាពសារព័ត៌មានធានាដល់បុគ្គល និងក្រុមផ្សេងៗ នូវសិទ្ធិក្នុងការប្រាប់រឿងរ៉ាវរបស់ពួកគេ ដោយមិនខ្លាចពីការតបត។ សេរីភាពសារព័ត៌មានផ្តល់សិទ្ធិអំណាចដល់សហគមន៍រងគ្រោះក្នុងការនិយាយ និងស្តាប់អំពីបញ្ហានានាដូចជាសិទ្ធិកម្មករ សិទ្ធិស្ត្រី និងអ្នកស្រលាញ់ភេទដូចគ្នា សិទ្ធិជនពិការ សិទ្ធិជនជាតិភាគតិច និងសាសនា ឬសិទ្ធិជនជាតិដើមភាគតិចជាដើម។ សេរីភាពសារព័ត៌មានផ្តល់នូវមធ្យោបាយសម្រាប់សហគមន៍ទាំងនេះក្នុងការបញ្ចេញមតិ និងដើម្បីតស៊ូមតិសម្រាប់ខ្លួនឯង និងអ្នកដទៃផងដែរ។

## ៤. ការគំរាមកំហែងដល់សេរីភាពសារព័ត៌មានជុំវិញពិភពលោក

ដោយសារតែព័ត៌មានដែលអ្នកសារព័ត៌មាន និងអ្នកធ្វើការខាងប្រព័ន្ធផ្សព្វផ្សាយធ្វើការផ្សព្វផ្សាយចេញទៅជាព័ត៌មានដែលអាចប៉ះពាល់ដល់ផលប្រយោជន៍របស់អ្នកមានអំណាច ឬដែលអាចបង្ហាញពីចំណុចខ្វះខាត ការខកខាន ឬកំហុសរបស់រដ្ឋាភិបាល ពេលខ្លះធ្វើឱ្យអ្នកសារព័ត៌មាន និងអ្នកធ្វើការខាងប្រព័ន្ធផ្សព្វផ្សាយទាំងនោះអាចត្រូវបានគេមើលឃើញថាជាការគំរាមកំហែងដែលត្រូវតែបំបិទ។ នៅជុំវិញពិភពលោក អ្នកសារព័ត៌មាន និងអ្នកធ្វើការខាងប្រព័ន្ធផ្សព្វផ្សាយប្រឈមមុខនឹងគ្រោះថ្នាក់ជាច្រើនប្រព្រឹត្តឡើងដោយអាជ្ញាធរ និងភាគីទីបី។

ខាងក្រោមនេះជាគ្រោះថ្នាក់មួយចំនួន ប៉ុន្តែមិនកម្រិតត្រឹមនេះទេ ៖

**ការយាយីតាមប្រព័ន្ធតុលាការ និងការដាក់ពន្ធនាគារ**

**ការយាយី និងការបំភិតបំភ័យតាមរយៈអ៊ីនធឺណិត និងផ្ទាល់**

**ការដាក់កំហិត និងការបិទព័ត៌មាន ឬគេហទំព័រ**

**ការឃុំខ្លួនតាមអំពើចិត្ត**

**ការវាយដំលើរូបរាងកាយ**

**ឃាតកម្ម ការបាត់ខ្លួនដោយបង្ខំ និងការធ្វើទារុណកម្ម ...**

## ៥. សេរីភាពសារព័ត៌មាននៅប្រទេសកម្ពុជា

សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពព័ត៌មានគឺជាសិទ្ធិមូលដ្ឋានដែលត្រូវបានធានាដោយច្បាប់ជាតិកម្ពុជា និងច្បាប់អន្តរជាតិ។ សេរីភាពសារព័ត៌មានគឺជាធាតុដ៏សំខាន់នៃសិទ្ធិទាំងនេះ ហើយជាសិទ្ធិដែលរងការគំរាមកំហែងកាន់តែខ្លាំងឡើងនៅជុំវិញពិភពលោក។ សូម្បីតែនៅក្នុងប្រទេសប្រជាធិបតេយ្យក៏ដោយ ក៏សេរីភាពសារព័ត៌មានអាចប្រឈមនឹងបញ្ហាជាច្រើនផងដែរ។



សេរីភាពសារព័ត៌មាននៅប្រទេសកម្ពុជាក៏មានការប្រឈមផងដែរ។ ចាប់តាំងពីឆ្នាំ១៩៩២ មកមានអ្នកសារព័ត៌មានត្រូវបានសម្លាប់។ អ្នកសារព័ត៌មានក៏ប្រឈមមុខនឹងការយាយីតាមប្រព័ន្ធតុលាការដោយសារសកម្មភាពរាយការណ៍ស្របច្បាប់របស់ពួកគេ អាជ្ញាប័ណ្ណផ្សព្វផ្សាយត្រូវបានដកហូតតាមអំពើចិត្ត អំពើហិង្សាលើរូបរាងកាយអ្នកសារព័ត៌មានមិនត្រូវបានផ្តន្ទាទោស ការបំភិតបំភ័យ និងការគំរាមកំហែងលើអ្នកសារព័ត៌មានក្លាយទៅជារឿងធម្មតា។ កត្តាទាំងនេះនាំឱ្យកម្ពុជាទទួលបានចំណាត់ថ្នាក់ទាបក្នុងសន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោកឆ្នាំ២០២១ របស់អង្គការអ្នកកាសែតគ្មានព្រំដែន ដែលទទួលបានចំណាត់ថ្នាក់លេខ១៤៤ ក្នុងចំណោម១៨០ប្រទេស។

## ៦. សេរីភាពសារព័ត៌មានក្រោមច្បាប់ជាតិ និងច្បាប់អន្តរជាតិ



### ច្បាប់ជាតិ

### រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

សិទ្ធិសេរីភាពខាងការបញ្ចេញមតិត្រូវបានការពារដោយ**មាត្រា៤១** នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា («រដ្ឋធម្មនុញ្ញ») ដែលបានចែងថា *"ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។"* **មាត្រា៣១** នៃរដ្ឋធម្មនុញ្ញផ្តល់ធម្មនុញ្ញភាពធម្មនុញ្ញដល់សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិដែលកម្ពុជាបានផ្តល់សច្ចាប័ន ដែលភាគច្រើនការពារសេរីភាពខាងការបញ្ចេញមតិ និងសេរីភាពសារព័ត៌មាន។

### ច្បាប់ស្តីពីរបបសារព័ត៌មាន ឆ្នាំ១៩៩៥ («ច្បាប់សារព័ត៌មាន»)

**មាត្រា១** *"ធានាសេរីភាពសារព័ត៌មាន និងសេរីភាពខាងការបោះពុម្ពផ្សាយ"* ស្របតាមមាត្រា៣១ និង ៤១ នៃរដ្ឋធម្មនុញ្ញ។

**មាត្រា៣** ធានាសិទ្ធិសេរីភាពពីការត្រួតពិនិត្យមុនពេលបោះពុម្ពផ្សាយ។

**មាត្រា៤** ធានាពីការមិនអាចត្រូវបានផ្តន្ទាទោសចំពោះការបោះពុម្ពផ្សាយព័ត៌មានផ្លូវការដែលសមស្របតាមសភាពពិតពេញលេញ ឬសេចក្តីសង្ខេបត្រឹមត្រូវតាមរឿងពិត។

**មាត្រា៥** ចែងអំពីសារព័ត៌មានមានសិទ្ធិទទួលបានព័ត៌មានដែលស្ថិតក្នុងការគ្រប់គ្រងរបស់រដ្ឋាភិបាល។

**មាត្រា២០** ធានាថាគ្មានជនណាម្នាក់ត្រូវប្រឈមនឹងការទទួលខុសត្រូវព្រហ្មទណ្ឌដោយសារការបញ្ចេញមតិឡើយ។

### ច្បាប់អន្តរជាតិ

មាត្រា១៩ នៃ**សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស** ចែងថា *"មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការមានមតិ និងការសម្តែងមតិ។ សិទ្ធិនេះ រាប់បញ្ចូលទាំង សេរីភាពក្នុងការប្រកាន់មតិដោយគ្មានការជ្រៀតជ្រែក និងសេរីភាពក្នុងការ**ស្វែករក ការទទួល និងការផ្សព្វផ្សាយព័ត៌មាន និងគំនិតនានា** ដោយគ្មានព្រំដែន ទោះតាមរយៈមធ្យោបាយសម្តែងមតិណាមួយក៏ដោយ។"*

មាត្រា១៩ នៃ**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ** ដែលកម្ពុជាជារដ្ឋភាគីនោះ តម្រូវឱ្យរដ្ឋភាគីទាំងអស់ធានានូវសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងព័ត៌មាន រាប់បញ្ចូលទាំងសិទ្ធិក្នុងការប្រកាន់មតិដោយគ្មានការជ្រៀតជ្រែក និង *"សិទ្ធិក្នុងការ**ស្វែងរក ការទទួល និងការផ្សព្វផ្សាយព័ត៌មាន និងគំនិតនានា** ដោយគ្មានព្រំដែន ទោះតាមរយៈមធ្យោបាយសម្តែងមតិណាមួយក៏ដោយ។"*

បន្ថែមលើសពីនេះទៅទៀត សេចក្តីពន្យល់ទូទៅលេខ៣៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ របស់គណៈកម្មាធិការសិទ្ធិមនុស្សបានបញ្ជាក់ពីមធ្យោបាយដែលរដ្ឋត្រូវតែប្រកាន់យកដើម្បីការពារសិទ្ធិអ្នកប្រើប្រាស់ព័ត៌មាន ជាពិសេសលើកទឹកចិត្តឱ្យមានប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងចម្រុះបែប។ ដូច្នេះ រដ្ឋាភិបាលមានកាតព្វកិច្ចលើកកម្ពស់ និងធានាឱ្យមានប្រព័ន្ធផ្សព្វផ្សាយចម្រុះ និងឯករាជ្យ។

## ៧. កំហិតផ្នែកច្បាប់ចំពោះសេរីភាពសារព័ត៌មាននៅកម្ពុជា



ទោះបីជាមានការការពារផ្លូវច្បាប់ក៏ដោយ ក៏អ្នកសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅកម្ពុជា នៅតែជាមុខសញ្ញានៃការយាយីនិងបំភិតបំភ័យ។ ខណៈពេលដែលច្បាប់ស្តីពីរបបសាព័ត៌មាន និងរដ្ឋធម្មនុញ្ញការពារសេរីភាពក្នុងការបញ្ចេញមតិក៏ដោយ ក៏ច្បាប់ ឬគោលនយោបាយជាតិផ្សេងទៀតមានការរឹតត្បិតចំពោះសេរីភាពក្នុងការបញ្ចេញមតិ និងសេរីភាពសារព័ត៌មានផងដែរ។

### ក្រមព្រហ្មទណ្ឌកម្ពុជា

**មាត្រា៣០៥** ពិន័យជាប្រាក់យ៉ាងច្រើន និងដាក់ទណ្ឌកម្មព្រហ្មទណ្ឌចំពោះអំពើបរិហារកេរ្តិ៍។ តាមមាត្រា៣០៥ បទបរិហារកេរ្តិ៍មានន័យថា *"គ្រប់ការអះអាងបំផ្លើស ឬការទំលាក់កំហុសដោយអសុទ្ធចិត្តលើអំពើណាមួយ ដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស ឬកិត្តិស័ព្ទនៃបុគ្គល ឬនៃស្ថាប័ន"*។

**មាត្រា៤៣៧(ស្ទួន)** ដាក់ទោសលើការប្រមាថចំពោះអង្គព្រះមហាក្សត្រ ដោយការពិន័យជាប្រាក់យ៉ាងច្រើន និងដាក់ទណ្ឌកម្មព្រហ្មទណ្ឌចំពោះបុគ្គលដែលប្រមាថព្រះមហាក្សត្រតាមរយៈ *"វាចា កាយវិការ សំណេរ គំនូរ ឬវត្ថុផ្សេងៗ"*។ លើសពីនេះ នីតិបុគ្គលរួមទាំងស្ថាប័នផ្សព្វផ្សាយ *"អាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទល្មើស ដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន"* តាមមាត្រា៤២។

ភាសាទូលំទូលាយនៃបទបញ្ញត្តិទាំងនេះ អនុញ្ញាតឱ្យអាជ្ញាធរអនុវត្តច្បាប់តាមអំពើចិត្ត និងរាំងអ្នកសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យពីការរាយការណ៍ព័ត៌មានត្រឹមត្រូវពាក់ព័ន្ធនឹងព្រះមហាក្សត្រ ស្ថាប័នរដ្ឋាភិបាល ឬមន្ត្រីមានអំណាច ដោយសារខ្លាចទទួលទណ្ឌកម្មព្រហ្មទណ្ឌ។

## ច្បាប់សារព័ត៌មាន

**មាត្រា១៤** ចែងអំពីការរឹតត្បិតចំពោះការបោះពុម្ពផ្សាយនូវអ្វីដែល *"ប៉ះពាល់ដល់ប្រពៃណីល្អរបស់សង្គមជាតិ"*។ ភាសាមិនច្បាស់លាស់ទាំងនេះអនុញ្ញាតឱ្យប្រព័ន្ធតុលាការមានអំណាចខ្លាំងក្នុងការបកស្រាយថាបទល្មើសមួយត្រូវបានប្រព្រឹត្តឬយ៉ាងណា។ មាត្រា១៣ អាចត្រូវបានអនុវត្តដើម្បីកំណត់មុខសញ្ញាចំពោះអ្នកសារព័ត៌មាន ឬប្រព័ន្ធផ្សព្វផ្សាយឯករាជ្យជុំវិញការរាយការណ៍ស្របច្បាប់របស់ពួកគេ។




## រដ្ឋធម្មនុញ្ញ

ការធ្វើវិសោធនកម្មមាត្រា៤២ និង៤៩ នៃរដ្ឋធម្មនុញ្ញកាលពីឆ្នាំ២០១៨ តម្រូវឱ្យគណបក្សនយោបាយ និងប្រជាពលរដ្ឋខ្មែរគ្រប់រូប *"ត្រូវតែអូល់ផលប្រយោជន៍ជាតិជាធំ"*។ ដូច្នេះសេរីភាពក្នុងការបញ្ចេញមតិអាចត្រូវបានចាត់ទុកថាមិនស្របតាមរដ្ឋធម្មនុញ្ញ ប្រសិនបើសេរីភាពនេះប៉ះពាល់ដោយផ្ទាល់ ឬប្រយោលដល់ "ផលប្រយោជន៍ជាតិ"។ វិសោធនកម្មទាំងនេះអាចរឹតត្បិតហួសហេតុលើអ្នកសារព័ត៌មានឯករាជ្យ។

## គោលនយោបាយ

កាលពីខែមករា ឆ្នាំ២០២១ អគ្គស្នងការនគរបាលជាតិបានចេញសេចក្តីណែនាំដល់នគរបាលរាជធានីនិងខេត្ត ហាមអ្នកសារព័ត៌មានមិនឱ្យថតការស៊ើបអង្កេតរបស់នគរបាលលើបទល្មើសព្រហ្មទណ្ឌ។ កាលពីខែតុលា ឆ្នាំ២០២១ នគរបាលរាជធានីភ្នំពេញបានបង្កើតគោលការណ៍មួយក្នុងការហាមអ្នកសារព័ត៌មានពីការផ្សាយផ្ទាល់នៅពេលអាជ្ញាធរ*"កំពុងអនុវត្តច្បាប់នៅតាមដងផ្លូវ"*។ គោលការណ៍ទាំងពីរនេះរឹតត្បិតដោយមិនអាចអនុញ្ញាតបានចំពោះសេរីភាពសារព័ត៌មាន៕

## សំណួរសាកល្បង

**១. តើអ្វីជាសេរីភាពសារព័ត៌មាន?**

☐ ក. សេរីភាពសារព័ត៌មាន គឺជាសមត្ថភាពក្នុងការស្វែងរក ទទួល និងចែកចាយព័ត៌មាន និង គំនិត។

☐ ខ. សេរីភាពសារព័ត៌មាន គឺជាសមត្ថភាពនៃការបញ្ចេញមតិដោយគ្មានការជ្រៀតជ្រែក។

☐ គ. សេរីភាពសារព័ត៌មាន គឺជាសិទ្ធិចែកចាយ និងផ្សព្វផ្សាយព័ត៌មានតាមរយៈវិទ្យុ និង ទូរទស្សន៍ ក្នុងទម្រង់បោះពុម្ពជាកាសែត ឬទស្សនាវដ្ដី តាមប្រព័ន្ធផ្សព្វផ្សាយសង្គម ឬប្រព័ន្ធឌីជីថលផ្សេងទៀត ដោយមិនមានការជ្រៀតជ្រែកពីរដ្ឋាភិបាល ឬភាគីទីបី។

**២. តើអ្វីជាសារព័ត៌មានសេរី និងឯករាជ្យ?**

☐ ក. សារព័ត៌មានសេរី និងឯករាជ្យចែកចាយ និងផ្សព្វផ្សាយព័ត៌មានដល់សាធារណៈជនក្រោមឥទ្ធិពលរដ្ឋាភិបាល ឬភាគីទីបីក្នុងគោលបំណងបម្រើផលប្រយោជន៍របស់រដ្ឋាភិបាល ឬ សាជីវកម្ម។

☐ ខ. សារព័ត៌មានសេរី និងឯករាជ្យចែកចាយ និងផ្សព្វផ្សាយព័ត៌មានដោយមិនមានការជ្រៀតជ្រែកពីរដ្ឋាភិបាល ឬភាគីទីបី ដោយផ្ដល់ព័ត៌មានដល់សង្គមតាមរយៈការស៊ើបអង្កេតបញ្ហានានា ធ្វើការវិភាគព័ត៌មាន ជំរុញឱ្យមានការពិភាក្សា និងត្រួតពិនិត្យអង្គហេតុនៃរឿងរ៉ាវ ដែលជួយឱ្យរដ្ឋាភិបាលទទួលខុសត្រូវចំពោះសកម្មភាពរបស់ពួកគេ។

**៣. សេរីភាពសារព័ត៌មានអនុញ្ញាតឱ្យមានការអនុវត្តសិទ្ធិទទួលព័ត៌មាន បើសិនសេរីភាពសារព័ត៌មានត្រូវបានរឹតត្បិត នោះការអនុវត្តសិទ្ធិទទួលព័ត៌មានក៏ត្រូវបានរឹតត្បិតដូចគ្នា។**

☐ ក. ត្រូវ

☐ ខ. ខុស

**៤. តើហេតុអ្វីបានជាសេរីភាពសារព័ត៌មានមានសារៈសំខាន់?**

☐ ក. សេរីភាពសារព័ត៌មានស៊ើបអង្កេតបញ្ហានានាដើម្បីផ្សព្វផ្សាយជាព័ត៌មាន គំនិត មតិយោបល់ និងទស្សនៈនានា ដែលជួយឱ្យរដ្ឋាភិបាលទទួលខុសត្រូវចំពោះសកម្មភាព ឬបង្ហាញពីកំហុសរបស់រដ្ឋាភិបាល។

☐ ខ. សេរីភាពសារព័ត៌មានជំរុញឱ្យមានសេរីភាពក្នុងការបញ្ចេញមតិ និងជួយឱ្យសង្គមប្រជាធិបតេយ្យរីកចម្រើន។

☐ គ. សេរីភាពសារព័ត៌មានធ្វើឱ្យប្រជាពលរដ្ឋបានដឹងអំពីព័ត៌មានដែលមានសារៈសំខាន់សម្រាប់ផលប្រយោជន៍សាធារណៈ និងពង្រឹងធិបតេយ្យភាព។

☐ ឃ. ចម្លើយ ក, ខ និង គ

៥. ការផ្សព្វផ្សាយព័ត៌មានដែលអាចប៉ះពាល់ដល់ផលប្រយោជន៍របស់អ្នកមានអំណាច ឬបង្ហាញពីចំណុចខ្វះខាតរបស់រដ្ឋាភិបាល ការខកខាន ឬកំហុស អាចត្រូវបានហាមឃាត់ដោយរដ្ឋាភិបាលដោយមិនបំពានលើសេរីភាពសារព័ត៌មានឡើយ។

☐ ក. ត្រូវ

☐ ខ. ខុស

៦. តើការគំរាមកំហែងណាខ្លះដែលអាចកើតមានឡើងចំពោះសេរីភាពសារព័ត៌មាន?

☐ ក. ការយាយីតាមប្រព័ន្ធតុលាការ និងការដាក់ពន្ធនាគារ;

☐ ខ. ការយាយី និងការបំភិតបំភ័យតាមរយៈអ៊ីនធឺណិត និងផ្ទាល់;

☐ គ. ការដាក់កំហិត និងការបិទព័ត៌មាន ឬគេហទំព័រ;

☐ ឃ. ចម្លើយ ក, ខ និង គ

៧. សេរីភាពសារព័ត៌មាន គឺជាសិទ្ធិមូលដ្ឋានដែលត្រូវបានធានាដោយច្បាប់ជាតិកម្ពុជា និងច្បាប់អន្តរជាតិ។ ទោះបីជាយ៉ាងនេះក្តី សេរីភាពសារព័ត៌មាននៅតែអាចរងការគំរាមកំហែង។

☐ ក. ត្រូវ

☐ ខ. ខុស

៨. ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។ តើមាត្រាណានៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាការពារសិទ្ធិនេះ?

☐ ក. មាត្រា ៣៩

☐ ខ. មាត្រា ៤០

☐ គ. មាត្រា ៤១

៩. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ចែងថា *"មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការមានមតិ និងការសម្តែងមតិ"។ សិទ្ធិនេះ រាប់បញ្ចូលទាំង សេរីភាពក្នុងការប្រកាន់មតិដោយគ្មានការជ្រៀតជ្រែក និងសេរីភាពក្នុងការស្វែករក ការទទួល និងការផ្សព្វផ្សាយព័ត៌មាន និងគំនិតនានា ដោយគ្មានព្រំដែន ទោះតាមរយៈមធ្យោបាយសម្តែងមតិណាមួយក៏ដោយ។"* តើមាត្រាមួយណានៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សបានលើកឡើងអំពីសិទ្ធិនេះ?

☐ ក. មាត្រា ៩

☐ ខ. មាត្រា ១០

☐ គ. មាត្រា ១៩

១០. មាត្រា១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលកម្ពុជាជារដ្ឋភាគីនោះ តម្រូវឱ្យរដ្ឋភាគីទាំងអស់ធានានូវសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងព័ត៌មាន រាប់បញ្ចូលទាំងសិទ្ធិក្នុងការប្រកាន់មតិដោយគ្មានការជ្រៀតជ្រែក និង *"សិទ្ធិក្នុងការស្វែងរក ការទទួល និងការផ្សព្វផ្សាយព័ត៌មាន និងគំនិតនានា ដោយគ្មានព្រំដែន ទោះតាមរយៈមធ្យោបាយសម្តែងមតិណាមួយក៏ដោយ។"*

☐ ក. ត្រូវ

☐ ខ. ខុស

# មេរៀនស្តីពី
# សេរីភាពសារព័ត៌មាននិងសិទ្ធិទទួលព័ត៌មាន




ឬ ស្កេនទីនេះ

## ចូលទៅកាន់មេរៀន

*https://sithi.org/km/*

*>វេទិកាអប់រំ*

*>>សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន*